**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ**

# សង្ខេប

# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨

## សេចក្តីផ្តើម

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** តម្រូវឱ្យមានអភិក្រមពហុវិស័យ និងសមាហរណកម្មមួយដែលគ្របដណ្តប់ទៅលើប្រធានបទអភិវឌ្ឍន៍ដ៏ទូលំទូលាយ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ យុទ្ធសាស្ត្រ គោលនយោបាយ និងការវិនិយោគនៅក្នុងវិស័យ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការគ្រប់គ្រងធនធានទឹក សុខភាព ទឹកស្អាត អនាម័យ អប់រំ និងកិច្ចគាំពារសង្គម សុទ្ធសឹងតែមានសារៈសំខាន់។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ត្រូវបានរៀបចំឡើង ដើម្បីបំពេញបន្ថែមដល់យុទ្ធសាស្ត្រ និង ផែនការតាមវិស័យដែលមានស្រាប់ សំដៅបំពេញចន្លោះប្រហោងនានា និងជាមូលដ្ឋានមួយសម្រាប់ការធ្វើសកម្មភាពអន្តរវិស័យរួមគ្នា ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ២០១៤-២០១៨** រួមមាន៖ ចក្ខុវិស័យរយៈពេលវែងមួយ គោលដៅមួយ និងគោលបំណងចំនួន៣។

**ចក្ខុវិស័យរយៈពេលវែង** *"ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវ័ន្តសង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់"។*

**គោលដៅរួម** *"ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សម្គាល់ ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាពនិងប្រកបដោយ អាហារូបត្ថម្ភ ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារនិងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេ មានសុខភាពល្អ និងមានផលិតភាពខ្ពស់"។*

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានគោលបំណងចំនួន៣** ព្រមទាំងអន្តរាគមន៍គន្លឹះជាអាទិភាព និងឧបករណ៍មួយចំនួន ដើម្បីសម្រេចឱ្យបាននូវគោលបំណងទាំងនោះ។

**ព័ត៌មានបន្ថែម៖** សូមទំនាក់ទំនងមកកាន់ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈទូរស័ព្ទលេខ: ០១២ ៩៥ ១១១១ ឬ អ៊ីមែល: soksilo@gmail.com

**គោលបំណងទី១** ៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង តាមរយៈផលិតកម្មកសិកម្ម និងការចិញ្ចឹមសត្វដែលកាន់តែមានភាពចម្រុះនិងផលិតភាពខ្ពស់ជាងមុន ការប្រើប្រាស់ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងតាមរយៈការងារដែលពុំមែនជាការងារកសិកម្មនិងឱកាសក្នុងការទទួលបានប្រាក់ចំណូល។

**គោលបំណងទី២** ៖ ធ្វើឱ្យមានភាពប្រសើរឡើងនូវការប្រើប្រាស់ និង ការបឺតស្រូបស្បៀង ដែលនាំឱ្យមានការកាត់បន្ថយនូវកង្វះអាហារូបត្ថម្ភ ក្នុងចំណោមកុមារ និងមាតា ព្រមទាំងលើកកម្ពស់ដល់ការអភិវឌ្ឍន៍មនុស្ស និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា។

**គោលបំណងទី៣៖** ធ្វើឱ្យប្រសើរឡើងប្រព័ន្ធសុវត្ថិភាពសង្គម និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងហានិភ័យ និងវិបត្តិនានា ដើម្បីបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង សម្រាប់គ្រួសារដែលមានបញ្ហាអសន្តិសុខស្បៀង។

## គោលបំណងទី១ ៖ បង្កើនការមានស្បៀង និងការទទួលបានស្បៀង

ការធ្វើប្រពលវប្បកម្ម និងពិពិធកម្មប្រព័ន្ធកសិកម្មខ្នាតតូច និងបង្កើនការទទួលបាននូវស្បៀងអាហារតាមរយៈប្រាក់ចំណូល (ផលិតកម្មកសិកម្មតាមតម្រូវការទីផ្សារ និង ការបង្កើតប្រភពប្រាក់ចំណូលដែលមិនមែនជាកសិកម្ម) គឺមានសារៈសំខាន់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងគ្រួសារ និងដើម្បីបង្កើនភាពធន់ទ្រាំរបស់ប្រជាពលរដ្ឋនៅតាមជនបទដែលមានបញ្ហាអសន្តិសុខស្បៀង ក្នុងការទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានដាក់ចូលចេញនូវសកម្មភាពជាអាទិភាពចំនួន៤ ដូចខាងក្រោម៖

*១. ប្រពលវប្បកម្ម ពិពិធកម្ម និង សមាហរណកម្មទីផ្សារនៃប្រព័ន្ធកសិកម្មខ្នាតតូចៈ* អន្តរាគមន៍នានាក្នុងការធ្វើប្រពលវប្បកម្ម និងធ្វើពិពិធកម្មកសិកម្មខ្នាតតូចនៅក្នុងប្រទេសកម្ពុជាមិនមែនជាបញ្ហាថ្មីៗទេ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** នឹងផ្តោតលើកិច្ចអន្តរាគមន៍សំខាន់ៗចំនួន៦ ដូចខាងក្រោម៖

១. ផ្តល់លទ្ធភាពដល់កសិករខ្នាតតូចដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ឱ្យទទួលបានបច្ចេកទេសសមស្រប អាចយកទៅអនុវត្តបាន ហើយមានតម្លៃទាប អាចយកមកធ្វើការកែសម្រួលបាន និងអាចចម្លងយកទៅប្រើប្រាស់នៅកន្លែងដ៏ទៃទៀត សម្រាប់ដំណាំស្រូវ និងកសិផលដ៏ទៃទៀត វារីវប្បកម្ម ផលិតកម្មបសុសត្វ និងបន្លែ ព្រមទាំងការរក្សាទុក និងការកែច្នៃកសិផល។
២. ផ្តល់លទ្ធភាពដល់កសិករដែលមានបញ្ហាអសន្តិសុខស្បៀង ដើម្បីទទួលបានប្រព័ន្ធធារាសាស្ត្រខ្នាតតូច ជាពិសេសនៅក្នុងតំបន់ដែលប្រឈមទៅនឹងគ្រោះរាំងស្ងួត។
៣. ធ្វើឱ្យប្រសើរឡើងនូវការទទួលបាន និងការប្រើប្រាស់សមស្របចំពោះធាតុចូលកសិកម្មដែលមានសុវត្ថិភាព និងគុណភាព សម្រាប់កសិករខ្នាតតូចដែលមានបញ្ហាអសន្តិសុខស្បៀង។
៤. លើកកម្ពស់លទ្ធភាពក្នុងការទទួលបានឥណទាន និងការសន្សំប្រាក់សម្រាប់កសិករខ្នាតតូច (គម្រោងមីក្រូហិរញ្ញវត្ថុ)
៥. ផ្សព្វផ្សាយយន្តការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច ឱ្យបានកាន់តែប្រសើរទៅនឹងទីផ្សារនិងអភិវឌ្ឍន៍ឱ្យមាននូវខ្សែសង្វាក់តម្លៃដែលជាប្រយោជន៍ដល់កសិករ។
៦. គាំទ្រការបង្កើតអង្គការកសិករនិងសហករណ៍កសិកម្ម ដើម្បីជំរុញការផលិតស្បៀងនិងប្រាក់ចំណូលគ្រួសារ។

*២. ការបែងចែកដីធ្លីនិងការផ្តល់កម្មសិទ្ធិជូនដល់ក្រុមគ្រួសារក្រីក្រនិងអសន្តិសុខស្បៀងៈ*

**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានដាក់ចេញនូវសកម្មភាពអាទិភាពចំនួន ៤ ដូចខាងក្រោម ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការទទួលបាននូវស្ថេរភាព សិទ្ធិកាន់កាប់ដីកសិកម្ម គឺជាប្រការសំខាន់មួយគាំទ្រដល់ការវិនិយោគក្នុងវិស័យកសិកម្ម និងដើម្បីការពារដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនិងអសន្តិសុខស្បៀង ។

១. ការពង្រីកការបែងចែកដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀង។
២. ជំរុញការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។
៣. ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់កសិករក្រីក្រដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ចំពោះសេវាគាំទ្រ វិស័យកសិកម្ម និងទីផ្សារ។
៤. លើកកម្ពស់ការគ្រប់គ្រង និងការអភិរក្សធនធានដីកសិកម្មសំដៅធានាឱ្យមានកំណើន ផលិតភាព និងនិរន្តរភាពនៃផលិតកម្មស្បៀងក្នុងប្រទេសកម្ពុជា។

*៣.ការលើកកម្ពស់លទ្ធភាពទទួលបាននិងការប្រើប្រាស់ប្រកបដោយនិរន្តភាពនៃធនធានជលផល និងព្រៃឈើសម្រាប់ប្រជាជនក្រីក្រនិងអសន្តិសុខស្បៀង:* ប្រាក់ចំណូលពីធនធានព្រៃឈើនិងជលផលគឺជាប្រភពមួយជាប់ប្រាស្រ័យនឹងជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀងជាពិសេស នឹងជួយឱ្យពួកគេអាចដោះស្រាយបានក្នុងស្ថានភាពគ្រាមានអសន្តិសុខស្បៀង ដែលបណ្តាលមកពីមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ ឬ វិបត្តិសង្គម-សេដ្ឋកិច្ច។ ដើម្បីទប់ស្កាត់ការកាប់ឈើនិង នេសាទខុសច្បាប់ និងដើម្បីធានានិរន្តរភាពធនធានជលផលនិងព្រៃឈើ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានដាក់ចេញសកម្មភាពអាទិភាពចំនួន៦ខាងក្រោម៖

១. បន្តលើកកម្ពស់វារីវប្បកម្ម និងការចិញ្ចឹមត្រីតាមវាលស្រែ ដើម្បីកាត់បន្ថយសម្ពាធទៅលើ ត្រីទឹកសាប ធម្មជាតិ។
២. ពង្រឹងប្រព័ន្ធគ្រប់គ្រងសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ ឱ្យមាននិរន្តរភាព ដើម្បីលើកកម្ពស់ ការទទួលទានស្បៀងអាហារប្រកបដោយគុណភាព និងការទទួលបានប្រាក់ចំណូលសម្រាប់ គ្រួសារដែលមានបញ្ហាអសន្តិសុខស្បៀង។
៣. លើកកម្ពស់ទំនាក់ទំនងរវាងទីផ្សារទេសចរណ៍នៅក្នុងតំបន់ទីក្រុង និងអ្នកភូមិដែលអាស្រ័យលើផលព្រៃឈើ ជាមួយនឹងសហគ្រាសនិងសិប្បកម្មខ្នាតតូច។
៤. ធានាឱ្យសហគមន៍ជនជាតិដើមភាគតិចមានលទ្ធភាពទទួលបានធនធានធម្មជាតិដូចជាព្រៃឈើ និងជលផល និងលើកកម្ពស់ការប្រើប្រាស់ដីតាមសហគមន៍ និងប្រព័ន្ធកសិរុក្ខកម្ម ។
៥. រក្សាតុល្យភាពរវាងប្រយោជន៍សេដ្ឋកិច្ច និងថ្លៃចំណាយផ្នែកសង្គម និងបរិស្ថានរបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ (វារីអគ្គិសនី) ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀង។
៦. ទប់ស្កាត់ការញុះញុងពីមជ្ឈដ្ឋាននានា ដែលតែងតែលើកទឹកចិត្ត និងជំរុញឱ្យប្រជាជនបន្តចូលកាប់ទន្ទ្រានរានយកដីព្រៃរបស់រដ្ឋធ្វើជាកម្មសិទ្ធិឯកជនខុសច្បាប់ (ជាពិសេសការកាប់ទន្ទ្រាននៅក្នុងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ)។

*៤.ធ្វើឱ្យប្រសើរឡើងនូវការងារដែលមានប្រាក់កម្រៃ និង ឱកាសរកបានប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋក្រីក្រនិងអសន្តិសុខស្បៀង:* តិចជាងមួយភាគបីនៃកម្លាំងពលកម្មកម្ពុជាទាំងមូល រកប្រាក់ចំណូលបានពីការងារដែលមានប្រាក់កម្រៃប្រចាំខែជាទៀងទាត់។ ការបង្កើតសហគ្រាសកសិ-អាជីវកម្ម និងកសិដ្ឋានដែលមានលក្ខណៈប្រកួតប្រជែងកាន់តែច្រើនតាមរយៈសកម្មភាពសំខាន់ៗចំនួន៦គឺមានសារៈសំខាន់ណាស់ក្នុងការស្រូបយកនូវកម្លាំងពលកម្មដែលកំពុងកើនឡើងនៅតាមជនបទ និងដើម្បីបង្កើតការងារ និងប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅជនបទ។ សកម្មភាព សំខាន់ៗទាំង ៦ រួមមាន៖

១. លើកកម្ពស់ការបណ្តុះបណ្តាលបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងអសន្តិសុខស្បៀងនៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ដើម្បីបង្កើនជំនាញ និងលទ្ធភាពក្នុងការទទួលបានការងារ។
២. ធ្វើឱ្យប្រសើរឡើងនូវជំនាញដែលចាំបាច់សម្រាប់សហគ្រាសកែច្នៃកសិកម្ម សម្បទានសេដ្ឋកិច្ច កសិកម្ម និងការធ្វើកិច្ចសន្យាកសិ-អាជីវកម្ម សម្រាប់បង្កើតឱកាសការងារ និងបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារអសន្តិសុខស្បៀងនៅជនបទ។
៣. លើកកម្ពស់កិច្ចគាំពារសង្គមនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធជាពិសេសសម្រាប់ស្ត្រី។
៤. លើកកម្ពស់(ជាពិសេស)សហគ្រិនជាស្ត្រីដែលចូលរួមនៅក្នុងសហគ្រាសខ្នាតតូច សិប្បកម្ម។ល។ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការទទួលបានទុននិងទីផ្សារ។

៥. ធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌនិយ័តកម្ម ព្រមទាំងលទ្ធភាពក្នុងការទទួលបានបច្ចេកវិទ្យា សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងពង្រីកកិច្ចគាំទ្រហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់សមាហរណកម្មរបស់ពួកគេទៅក្នុងខ្សែសង្វាក់តម្លៃសកល។

៦. បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងទីផ្សារ ជាពិសេសនៅក្នុងតំបន់ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង និងបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំជួយពង្រីក និងថែរក្សាបណ្ដាញផ្លូវលំជនបទនៅក្នុងសហគមន៍ ។

## គោលបំណងទី២ ៖ ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងការបឺតស្រូបស្បៀង

គោលបំណងទី ២ នៃ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** មានបំណងជាចម្បងក្នុងការធ្វើឱ្យប្រសើរឡើងនៃស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ។ ការផ្តោតការយកចិត្តទុកដាក់ គឺនៅលើ **"ច្រកនៃឱកាស"** ក្នុងអំឡុងពេលមានផ្ទៃពោះនិងរយៈពេលពីរឆ្នាំដំបូងនៃជីវិតនៅពេលកង្វះអាហារូបត្ថម្ភរបស់កុមារមានលក្ខណៈគ្រោះថ្នាក់បំផុត ហើយការវិនិយោគក្នុងដំណាក់ការនេះនឹងផ្តល់ផលប្រយោជន៍ខ្ពស់បំផុតមកសង្គម និងសេដ្ឋកិច្ច។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ផ្តោតជាសំខាន់ទៅលើ៥ចំណុច៖

*១.ពង្រីកសេវាអាហារូបត្ថម្ភនិងការអប់រំអាហារូបត្ថម្ភ:* យុទ្ធសាស្ត្រនេះនឹងបំពេញបន្ថែមទៅលើអន្តរាគមន៍ដែលមានស្រាប់ ដូចជាការផ្ទេរសាច់ប្រាក់ទៅឱ្យជនក្រីក្រ ដើម្បីជំរុញតម្រូវការការថែទាំមុននិងក្រោយពេលសម្រាល, ការផ្តល់ស្បៀងអាហារដល់ប្រជាពលរដ្ឋក្រីក្រ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានអាហារដែលមានជីវជាតិបន្ថែម និងដើម្បីផ្សព្វផ្សាយយុទ្ធនាការអប់រំស្តីពីអាហារូបត្ថម្ភនឹងត្រូវបានអនុវត្ត ផ្សារភ្ជាប់ជាមួយនឹងសកម្មភាពអាទិភាពចំនួន ៨ រួមមាន៖

១. ធានាឱ្យមាននូវការគ្របដណ្តប់កាន់តែប្រសើរចំពោះការថែទាំ និងការផ្តល់ប្រឹក្សាចាំបាច់នានា អំពីបញ្ហាអាហារូបត្ថម្ភក្នុងអំឡុងពេល ១០០០ ថ្ងៃដំបូង ចាប់ពីពេលមានផ្ទៃពោះរហូតដល់កុមារមានអាយុ២ឆ្នាំ នៅឯមណ្ឌលសុខភាព (ការពិនិត្យផ្ទៃពោះមុនសម្រាល ពេលសម្រាល ការថែទាំក្រោយសម្រាល ការតាមដាន និងការលើកកម្ពស់ការលូតលាស់របស់កុមារអាយុក្រោម២ឆ្នាំ ការថែទាំព្យាបាលកង្វះអាហារូបត្ថម្ភស្រួចស្រាវ និងបញ្ហាអាហារូបត្ថម្ភ ក្នុងលក្ខណៈជាផ្នែកមួយនៃសមាហរណកម្មទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ ។

២. អនុវត្តយុទ្ធនាការផ្សព្វផ្សាយចម្រុះ ដើម្បីផ្លាស់ប្តូរឥរិយាបថ ការអនុវត្ត និងទម្លាប់ ចំពោះបញ្ហាអាហារូបត្ថម្ភសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា (បន្តកិច្ចខិតខំទៅលើការឆាប់បំបៅដោះកូន និងការបំបៅដោះកូនតែមួយមុខគត់ បង្កើនកិច្ចខិតខំដើម្បីលើកកម្ពស់ការបន្តបំបៅដោះកូនរហូតដល់អាយុ២ឆ្នាំ បង្កើនកិច្ចខិតខំក្នុងការផ្តល់អាហារបន្ថែមសមស្របជូនដល់កុមារអាយុចន្លោះពី ៦-២៣ខែ ផ្តល់ព័ត៌មានអំពីគ្រោះថ្នាក់នៃការចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត ព្រមទាំងសារៈសំខាន់នៃទឹកមានសុវត្ថិភាព និងអនាម័យ ដើម្បីឱ្យអាហារូបត្ថម្ភកាន់តែមានភាពប្រសើរឡើង។

៣. ត្រួតពិនិត្យឱ្យបានដិតដល់ទៅលើការកើនឡើងនៃនិន្នាការប្រើប្រាស់ និងចិញ្ចឹមកូនដោយទឹកដោះសិប្បនិម្មិត និងបង្កើតឱ្យមាននូវគណៈកម្មការឃ្លាំមើលមួយ ដើម្បីជួយដល់ការអនុវត្តអនុក្រឹត្យ លេខ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារតូច ដើម្បីទប់ស្កាត់ការប្រើប្រាស់ទឹកដោះសិប្បនិម្មិត និងពន្លឿនការអនុវត្តអនុក្រឹត្យនេះ ។

៤. ដើម្បីរៀបចំនិងអនុវត្តផែនការពង្រីកនិងធានាឱ្យមាននូវការផ្គត់ផ្គង់ទៀងទាត់នូវម្សៅមីក្រូសារជាតិចម្រុះសម្រាប់កុមារអាយុចន្លោះពី ៦-២៣ខែ ។

៥. ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំនៅលើការប្រើប្រាស់ថ្នាំគ្រាប់មីក្រូសារជាតិ យោងតាមសេចក្តីណែនាំអន្តរជាតិ។

៦. ពង្រីកគោលដៅផ្តល់អាហារបន្ថែមសម្រាប់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងកុមារអាយុ ៦-២៣ខែ នៅក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ។

៧. បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងដើម្បីលើកកម្ពស់ការយល់ដឹងនិងការលើកឡើងបញ្ហា និងផលវិបាកនៃការលើសអាហារូបត្ថម្ភនៅកម្ពុជា។

៨. បង្កើនសមត្ថភាពធនធានមនុស្សសម្រាប់បញ្ហាអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាល និងវិស័យដទៃទៀត។

*២. ធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ:* កង្វះការទទួលបានទឹកមានសុវត្ថិភាព និងជាពិសេស អនាម័យ និងការអនុវត្តខ្វះអនាម័យរបស់ប្រជាពលរដ្ឋក្រីក្រនឹងបង្កើន អត្រាជំងឺរាគរូស និងប្រេវ៉ាឡង់ប៉ារ៉ាសិតដែលបណ្តាលឱ្យបាត់បង់សារធាតុចិញ្ចឹមនិងធ្វើឱ្យការជ្រួតជ្រាបនៃអាហារមានកម្រិតទាប។ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកដែលមានសុវត្ថិភាពនិងអនាម័យរបស់ប្រជាពលរដ្ឋនៅតាមជនបទ (ដោយបង្កើនការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធក៏ដូចជាការបង្កើនការយល់ដឹងលើការប្រើប្រាស់ទឹកសមស្រប និងការអនុវត្តអនាម័យ) គឺជាអន្តរាគមន៍ដ៏មានអាទិភាពខ្ពស់ក្នុង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ដែលមានសកម្មភាពសំខាន់ៗដូចខាងក្រោម៖

១. បញ្ចូលនូវទិដ្ឋភាពទាំងអស់ ដែលទាក់ទងទៅនឹងទឹកស្អាត និងអនាម័យ ទៅក្នុងរាល់កម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ និងជាពិសេសនៅក្នុងកម្មវិធីអាហារូបត្ថម្ភតាមសហគមន៍។
២. ផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពអប់រំ និងអនុវត្តយុទ្ធនាការ ផ្លាស់ប្តូរឥរិយាបថតាមរយៈការភ្ជាប់ទំនាក់ទំនងកម្មវិធីទៅនឹងកម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ។
៣. ធ្វើសមាហរណកម្មផែនការវិនិយោគ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីទឹកស្អាតនិងអនាម័យ ជាមួយកម្មវិធីជាតិអាហារូបត្ថម្ភមាតានិងកុមារ។
៤. ធ្វើឱ្យប្រសើរឡើងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ព្រមទាំងពង្រឹងការគ្រប់គ្រងតាមសហគមន៍ (ប្រតិបត្តិការ និងការថែទាំ) នៅកម្រិតថ្នាក់ភូមិ ។

*៣. ពង្រីកការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ:* ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារសំខាន់ៗជាដំណោះស្រាយមួយដែលប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត និងនិរន្តរភាព ដើម្បីបង្ការបញ្ហាកង្វះមីក្រូសារជាតិ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការមានស្បៀងអាហារដែលមានបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយបន្ថែមទៀត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងគាំទ្រក្នុងការបង្កើតបទប្បញ្ញត្តិ និងយន្តការទៅលើការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារជាមួយនឹងអន្តរាគមន៍សំខាន់ចំនួន៨ ដូចខាងក្រោម៖

១. លើកកម្ពស់ការប្រើប្រាស់ស្បៀងអាហារដែលមានបញ្ចូលមីក្រូសារជាតិ តាមរយៈការបង្កើនចំណេះដឹងអំពីសារៈសំខាន់នៃស្បៀងអាហារដែលបានបញ្ចូលមីក្រូសារជាតិ នៅតាមមូលដ្ឋាន និងទូទាំងប្រទេស។
២. រៀបចំគោលនយោបាយជាតិ គោលការណ៍ណែនាំបច្ចេកទេស (បទដ្ឋានជាតិស្តីពីកម្រិតបញ្ចូលមីក្រូសារជាតិ) និងនិយ័តកម្មពាក់ព័ន្ធស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ ព្រមទាំងលើកកម្ពស់ការអនុវត្ត និងប្រសិទ្ធភាពនៃនិយ័តកម្មដែលមានស្រាប់។
៣. រៀបចំលិខិតបទដ្ឋានគតិយុត្តិ ដើម្បីគ្រប់គ្រងចំណីអាហារដែលបញ្ចូលមីក្រូសារជាតិទាំងផលិតក្នុងស្រុក និងការនាំចូល។
៤. ធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ និងធានាគុណភាពផលិតផលដែលត្រូវបានបញ្ចូលមីក្រូសារជាតិ (អំបិលអ៊ីយ៉ូដ ទឹកត្រី និងទឹកស៊ីអ៊ីវ)។
៥. ពង្រឹងការអនុវត្តអនុក្រឹត្យលេខ៦៩អនក្រ.បក ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដឱ្យមានប្រសិទ្ធភាព។
៦. ពង្រីកការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី និងទឹកស៊ីអ៊ីវ និងរៀបចំនិងអនុវត្តច្បាប់ដែលធ្វើឱ្យការបញ្ចូលជាតិដែកទៅក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ ជាល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការនាំចូល និងផលិតកម្មក្នុងស្រុក។
៧. ពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ និងផលិតផលសមស្របដ៏ទៃទៀត (ដូចជា អង្ករ និងប្រេងឆា) និងធានានូវគុណភាព សុវត្ថិភាព និងបរិមាណសមស្របតាមតម្រូវការ។
៨. បន្តអភិវឌ្ឍ និងជំរុញផលិតផលអាហារដែលបញ្ចូលមីក្រូសារជាតិបន្ថែម ឬអាហារបំប៉នសមស្រប នៅក្នុងស្រុក តាមរយៈវិស័យឯកជន។

*៤. បង្កើនការមាន និង ការប្រើប្រាស់ស្បៀងអាហារដែលមានជីវជាតិឱ្យបានសមស្រប:* ការធ្វើឱ្យប្រសើរឡើងនូវការមានស្បៀងអាហារដែលមានជីវជាតិ និងសុវត្ថិភាពនៅកម្រិតគ្រួសារ តាមរយៈការលើកកម្ពស់ប្រព័ន្ធផលិតកម្មកសិកម្មខ្នាតតូច(រួមទាំង សួនបន្លែ/ចម្ការឈើហូបផ្លែ ការអភិវឌ្ឍការចិញ្ចឹមសត្វ និងវារីវប្បកម្ម)ក៏ដូចជាការលើកកម្ពស់ចំណេះដឹងស្តីពីអាហារូបត្ថម្ភនៅក្នុងសហគមន៍ដើម្បីប្រើប្រាស់ និងរៀបចំអាហារដែលមានជីវជាតិនៅតាមមូលដ្ឋានតម្រូវឱ្យមានអន្តរាគមន៍ទាំង៣ ដូចខាងក្រោម៖

១. លើកកម្ពស់ការយល់ដឹងអំពីតម្លៃអាហារូបត្ថម្ភដែលមាននៅក្នុងផលិតផលកសិកម្មក្នុងស្រុកជូនដល់សហគមន៍ និងបញ្ជ្រាបបញ្ហាអាហារូបត្ថម្ភទៅក្នុងការផ្សព្វផ្សាយកសិកម្ម។
២. ពង្រីកកម្មវិធីលើកកម្ពស់ផលិតកម្មស្បៀងចម្រុះ ការរក្សាទុក ការកែច្នៃនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងសាលារៀន ព្រមទាំងភ្ជាប់ទំនាក់ទំនងកម្មវិធីទាំងនេះ ទៅនឹងវិស័យសុខាភិបាល។
៣. រៀបចំ និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីលើកកម្ពស់ផលិកម្មកសិកម្ម និងអាហារូបត្ថម្ភ ដើម្បីឱ្យសុខភាព និងបរិស្ថានកាន់តែមានភាពល្អប្រសើរ និងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពចំណីអាហារ រួមទាំងបទដ្ឋានអនាម័យ និង ហ្វីតូ-អនាម័យ និងបង្កើនការយល់ដឹងជាសាធារណៈអំពីសុវត្ថិភាពចំណីអាហារ។

*៥. តភ្ជាប់ឧបករណ៍គាំពារសង្គមទៅនឹងអាហារូបត្ថម្ភ:* ភាពក្រីក្រកំពុងធ្វើឱ្យកុមារជួបប្រទះនឹងបញ្ហាកង្វះអាហារូបត្ថម្ភដូច្នេះហើយ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** បានដាក់ចេញនូវសកម្មភាពអាទិភាពចំនួន៤ ត្រូវបានអនុវត្ត។

១. ធានាការសម្របសម្រួលយ៉ាងជិតស្និតរវាងកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ និងកម្មវិធីគាំពារសង្គមដែលទាក់ទងទៅនឹងអាហារូបត្ថម្ភ ជាមួយកម្មវិធីជាតិអាហារូបត្ថម្ភ និងកិច្ចអន្តរាគមអាហារូបត្ថម្ភដែលនឹងមាននៅតាមសហគមន៍។
២. កាត់បន្ថយរបាំងហិរញ្ញវត្ថុ ដែលរាំងស្ទះដល់ការថែទាំអាហារូបត្ថម្ភនៅមណ្ឌលសុខភាពតាមរយៈការពង្រីកមូលនិធិសមធម៌សុខភាព និងការគ្របដណ្តប់ទៅលើរាល់សេវា និងការថែទាំអាហារូបត្ថម្ភទាំងអស់ ក្រោមមូលនិធិសមធម៌សុខភាព។
៣. ភ្ជាប់ទំនាក់ទំនងកម្មវិធីសាធារណការ ដើម្បីធ្វើឱ្យទឹកមានសុវត្ថិភាព និងអនាម័យកាន់តែមានភាពប្រសើរឡើង។
៤. បង្កើនអាហារូបត្ថម្ភតាមរយៈកម្មវិធីសំណាញ់សុវត្ថិភាពសង្គមដែលមានស្រាប់ ដូចជាការផ្តល់អាហារនៅតាមសាលារៀន និងការរៀបចំចងក្រងបញ្ជីក្រុមអាហារដែលសម្បូរអាហារូបត្ថម្ភសម្រាប់ការអន្តរាគមទៅគោលដៅទាំងឡាយ។

## គោលបំណងទី៣ ៖ បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ

គ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់ និងភាពរាំងស្ងួត) វិបត្តិសង្គម-សេដ្ឋកិច្ច (ដូចជាការកើនឡើងតម្លៃស្បៀងអាហារយ៉ាងឆាប់រហ័ស) ឬវិបត្តិបុគ្គល (ភាពអត់ការងារធ្វើ ឬ ជំងឺ) អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថេរភាពក្នុងទទួលបានស្បៀងអាហារសម្រាប់គ្រួសារក្រីក្រ ហើយជាញឹកញាប់លេចមានវិធីសាស្ត្រ ដោះស្រាយមានលក្ខណៈប្រថុយប្រថាន ដែលនឹងនាំឱ្យក្រុមគ្រួសារក្រីក្រទាំងនោះជួបបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ។ ដើម្បីបង្កើនស្ថេរភាពស្បៀង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បានដាក់ចេញនូវកម្មវិធីអាទិភាពដូចខាងក្រោម៖

*១. ពង្រីកសន្តិសុខស្បៀងទាក់ទងនឹងឧបករណ៍គាំពារសង្គម:* រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍សំខាន់ៗទាំង៥ ដើម្បីធ្វើឱ្យប្រសើរឡើង នូវស្ថេរភាពទទួលបានស្បៀងអាហារ និងភាពធន់ទ្រាំរបស់ក្រុមគ្រួសារអសន្តិសុខស្បៀង ដើម្បីដោះស្រាយហានិភ័យ និងវិបត្តិនានា។

១. សាកល្បង និងពង្រីកកម្មវិធីសាធារណៈការមួយនៅកម្រិតថ្នាក់ជាតិ ដើម្បីលើកកម្ពស់ឱកាសការងារដែលអាចព្យាករណ៍ទុកជាមុនបានសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសហគមន៍និងតំបន់ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាពិសេសនៅរដូវពុំមានភាពមមាញឹកនៅក្នុងវិស័យកសិកម្ម និងផ្តល់ការគាំទ្រជីវភាពរស់នៅ និងការបង្កើតប្រាក់ចំណូលសម្រាប់ប្រជាពលរដ្ឋងាយរងគ្រោះបំផុត។
២. រៀបចំផែនការយថាភាព ដើម្បីពង្រីកការងារប្រើកំលាំងពលកម្មក្នុងអំឡុងពេលមានវិបត្តិ និងភ្ជាប់ទៅនឹងការត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ព្រមទាំងផែនការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

៣. អនុវត្ត និងពង្រីកការសាកល្បងកម្មវិធីផ្ទេរសាច់ប្រាក់មានល័ក្ខខ័ណ្ឌ ដើម្បីសម្រួលដល់ការប្រើប្រាស់ស្បៀងអាហាររបស់ក្រុមគ្រួសារអសន្តិសុខស្បៀង និងធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភកុមារ និងមាតា។

៤. បន្ត និងពង្រីក ការផ្តល់អាហារនៅតាមសាលារៀន នៅក្នុងតំបន់ក្រីក្រ និងអសន្តិសុខស្បៀង និងផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងបង្កើនភាពជាម្ចាស់របស់រដ្ឋាភិបាលក្នុងកម្មវិធីទាំងនោះ។

៥. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលកម្មវិធីសំណាញ់សុវត្ថិភាពសង្គម ដែលផ្តោតគោលដៅទៅលើក្រុមគ្រួសារអសន្តិសុខស្បៀងរវាងវិស័យនានា និងពង្រីកការសាកល្បង ដើម្បីលើកកម្ពស់សមាហរណកម្មកម្មវិធីគាំពារសង្គម ដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន។

## *២. ធ្វើឱ្យប្រសើរឡើងនូវភាពធន់ទ្រាំរបស់គ្រួសារទៅនឹងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ:*

ការពង្រឹងភាពធន់ទ្រាំរបស់សហគមន៍ឆ្លើយតបនឹងផលប៉ះពាល់ពីគ្រោះធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុដែលបានជះឥទ្ធិពលទៅលើសន្តិសុខស្បៀងគ្រួសារគឺជាកត្តាសំខាន់ និងកំពុងកើតមានឡើង ហើយសកម្មភាពសំខាន់ៗចំនួន៦ ដូចខាងក្រោមនេះ ត្រូវការជាចាំបាច់អភិវឌ្ឍ និងពង្រីកបន្ថែម។

១. អភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិព្រមទាំងបញ្ចូលបញ្ហាទាំងនេះទៅក្នុងយុទ្ធសាស្ត្រតាមវិស័យនិងផែនការតំបន់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុទៅលើសន្តិសុខស្បៀងរបស់គ្រួសារ។

២. ពង្រឹងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ទៅនឹងវិបត្តិស្បៀងអាហារ (ធានាការផ្គត់ផ្គង់ស្បៀង និងជំនួយផ្សេងៗ) ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃការឆ្លើយតបចំពោះគ្រោះអាសន្ន រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។

៣. ធ្វើឱ្យប្រសើរឡើងនូវភាពធន់ទ្រាំរបស់សហគមន៍ ទៅនឹងគ្រោះមហន្តរាយ និងវិបត្តិសេដ្ឋកិច្ច ដោយលើកកម្ពស់ការសន្សំប្រាក់ និងគម្រោងឥណទានតាមសហគមន៍ (ធនាគារស្រូវ និងមីក្រូហិរញ្ញវត្ថុ) ប្រព័ន្ធស្រោចស្រពខ្នាតតូច និងគម្រោងសហគមន៍បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

៤. សម្រួល និងធ្វើសមាហរណកម្មព័ត៌មានដែលមានស្រាប់ ប្រព័ន្ធបែងចែកចំណាត់ថ្នាក់ និងឧបករណ៍ជូនដំណឹងជាមុនព្រមទាំងការប៉ាន់ប្រមាណទៅលើផលប៉ះពាល់នៃគ្រោះមហន្តរាយ។

៥. បង្កើត និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនូវស្បៀងបំរុងជាតិ (គ្រាប់ពូជ) ដើម្បីផ្តល់ស្បៀង និងគ្រាប់ពូជទាន់ពេលវេលា ជូនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច និងការកើនឡើងតម្លៃស្បៀង។

៦. ថែរក្សា និងស្តារប្រឡាយ ទន្លេ និងបឹងធម្មជាតិ សម្រាប់កាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត។

## ការរៀបចំស្ថាប័នសម្រាប់សម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** បន្ថែមតម្លៃតាមរយៈការផ្តល់នូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដើម្បីជួយដល់បណ្តាក្រសួង-ស្ថាប័ននានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តអន្តរាគមន៍អាទិភាព ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងលក្ខណៈមួយប្រកបដោយប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិ។ គោលការណ៍ណែនាំ និងសកម្មភាពអាទិភាព ដើម្បីធ្វើឱ្យប្រសើរឡើង **យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និងបន្តអភិវឌ្ឍន៍ការរៀបចំស្ថាប័នទាក់ទងទៅនឹង៖

- ការសម្របសម្រួល និងការឃ្លាំមើលទៅលើគោលនយោបាយសម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

- ការត្រួតពិនិត្យ និងវាយតម្លៃទៅលើ**យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** និងកម្មវិធីរបស់យុទ្ធសាស្ត្រនេះ។
- ការបង្កើតអង្គភាពទទួលបន្ទុកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដូចជា៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងផែនការ និងក្រសួងកិច្ចការនារី។
- ការគ្រប់គ្រងចំណេះដឹង និងព័ត៌មាន ដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការជ្រើសរើសអ្នកទទួលផល និងការកំណត់គោលដៅអន្តរាគមន៍ លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការកសាងសមត្ថភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សកម្មភាពពង្រឹងស្ថាប័ន ៖

- **សកម្មភាពទី១៖** ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងនាមជាស្ថាប័ន រៀបចំគោលនយោបាយ និងលើកកម្ពស់ការសម្របសម្រួល និងសមាហរណកម្មការងារដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ។
- **សកម្មភាពទី២៖** ពង្រឹងក្រុមការងារបច្ចេកទេសគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីសម្របសម្រួលគម្រោង និងកម្មវិធីឱ្យមានប្រសិទ្ធភាព ដោយផ្អែកលើអាទិភាពដែលត្រូវបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទូទាំងវិស័យនានា និងលើកកម្ពស់ការធ្វើសុខដុមនីយកម្ម និងការតម្រឹមកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍន៍សម្រាប់បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- **សកម្មភាពទី៣៖** ធានាឱ្យមានការសម្របសម្រួលកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រកបដោយប្រសិទ្ធភាព រវាង ក្រសួង-ស្ថាប័ននានា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅកម្រិតថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។
- **សកម្មភាពទី៤៖** កែសម្រួល និងធ្វើការច្របាច់បញ្ចូលគ្នានូវក្របខ័ណ្ឌសូចនាករយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្អែកលើកម្រងសូចនាករមួយ និងគោលដៅជាក់ស្តែង ដែលស្របទៅនឹងយុទ្ធសាស្ត្រ និងផែនការតាមវិស័យពាក់ព័ន្ធដែលមានស្រាប់។
- **សកម្មភាពទី៥៖** បង្កើតកម្មវិធី ត្រួតពិនិត្យ និង វាយតម្លៃ និងយន្តការផ្តល់របាយការណ៍សមស្រប ដើម្បីធានាឱ្យការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាពនិងដើម្បីផ្តល់មតិយោបល់ត្រឡប់ផ្អែកលើ ភស្តុតាងក្នុងគោលបំណងអភិវឌ្ឍន៍កម្មវិធី និងអន្តរាគមន៍បន្ថែមទៀត។
- **សកម្មភាពទី៦៖** ពង្រឹងសមាហរណកម្ម និងការធ្វើសុខដុមនីយកម្មនៃការគ្រប់គ្រងចំណេះដឹង និងព័ត៌មាន អំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងប្រទេសកម្ពុជា តាមរយៈការពង្រឹងទំនាក់ទំនងរវាងប្រព័ន្ធ អភិក្រម និងផលិតផលផ្សេងៗគ្នា ដើម្បីបង្ហាញអំពីព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានសង្គតភាព និងត្រូវបានច្របាច់បញ្ចូលគ្នា ជូនដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។
- **សកម្មភាពទី៧៖** ពង្រឹងសមត្ថភាពក្នុងការវិភាគទិន្នន័យដែលទាក់ទងទៅនឹង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងផ្តល់នូវធនធានដែលអាចព្យាករណ៍ជាមុនបាន សម្រាប់ភារកិច្ចនេះ ដើម្បីលើកកម្ពស់និរន្តរភាព។
- **សកម្មភាពទី៨៖** លើកកម្ពស់ការប្រើប្រាស់ផលិតផលព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់រៀបចំផែនការ និងធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- **សកម្មភាពទី៩៖** កែសម្រួលឡើងវិញទៅលើកម្មវិធីបណ្តុះបណ្តាលអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្អែកលើ ការប៉ាន់ប្រមាណទៅលើផលប៉ះពាល់ និងការពង្រីកការបណ្តុះបណ្តាលនៅកម្រិតថ្នាក់ក្រោមជាតិ តាមរយៈប្រព័ន្ធបណ្តុះបណ្តាលបន្ត។
- **សកម្មភាពទី១០៖** ភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍសមត្ថភាពសម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតថ្នាក់ក្រោមជាតិ ទៅនឹងសមាសធាតុផ្នែកកសាងសមត្ថភាពដែលមានស្រាប់ នៅក្នុងបរិបទនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលបានមើលឃើញទុកជាមុននៅក្នុងបរិបទនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា និងកម្មវិធីជាតិដ៏ទៃទៀត។
- **សកម្មភាពទី១១៖** រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្សដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីលើកកម្ពស់សមត្ថភាពជារួមសម្រាប់ការងារសម្របសម្រួលលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងការឃ្លាំមើលគោលនយោបាយនៅកម្រិតថ្នាក់ជាតិ។
- **សកម្មភាពទី១២៖** ធ្វើឱ្យប្រសើរឡើងនូវការកំណត់គោលដៅអន្តរាគមន៍លើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈ៖ ការអភិវឌ្ឍនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់ប្រព័ន្ធមួយដែលមានសង្គតភាព សំដៅកំណត់អត្តសញ្ញាណជនក្រីក្រ នៅតំបន់ទីក្រុង និងជនដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀង។

**ព័ត៌មានបន្ថែម៖** សូមទំនាក់ទំនងមកកាន់ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈទូរស័ព្ទលេខ: ០១២ ៩៥ ១១១១ ឬ អ៊ីមែល: soksilo@gmail.com